P N K S

# NEWSLETTER



## Growing with Purpose: From Silence to Leadership

*Srey Pha from Kampong Pang Village, Kang Cham Commune, shares that before joining the PNKS-supported SKYE Youth Club, her life was limited to household work, and she had no confidence to speak in public or engage in community activities. She had no personal income and rarely imagined a future beyond her home. Through PNKS trainings and ongoing encouragement, Sreypha gradually found her voice, built confidence, and began actively participating in youth and community initiatives. This personal transformation opened new opportunities, and in June 2025 she secured paid employment with Amino-G Eco Handicraft Company. From earning no independent income before, she now has a stable income to supporting herself and her family while contributing her skills in video editing and communication across five provinces. Today, Sreypha stands as a confident young woman with dignity, purpose, and hope for the future.*

## From Exclusion to Leadership: Rin Rom's Journey of Hope and Dignity

Before joining PNKS, Mr. Rin Rom lived quietly on the margins of his community, carrying not only the challenges of farming but also the weight of being overlooked because of his disability. Today, his small farm tells a very different story. With support from PNKS, he became a model farmer and received a 6 x 15-meter net house. Inside it, he carefully tends to beds of water spinach, mustard greens, and Chinese kale. From his harvest, he has already sold 15 kilograms of vegetables, earning 60,000 riel (14.83USD), and continues to produce and sell vegetables daily. This income helps him buy school supplies for his children, seeds for the next planting, and food for his family, turning his land into a source of dignity and hope.

Beyond farming, the greatest change in Mr. Rin Rom's life is how he is now seen and how he sees himself. Once excluded from meetings and community discussions, he now stands as the Deputy Leader of the Community Initiative Development Group (CIDG). Through leadership training, technical farming sessions, resource mobilization workshops, and disability awareness seminars, his confidence has grown. Today, organizations such as ADRA and Plan recognize his potential and trust him as a focal point. From being silenced to becoming a leader, Mr. Rin Rom's journey shows that when people are given opportunity, respect, and belief, they can rise — not only for themselves, but for their whole community.



# CAMPING YOUTH FOR BOTH PROJECT

PNKS along with EHE Organization facilitated a a youth camping event under the theme “Youth as the Next Generation in Protecting Natural and Biological Resources for the Planet” at Siem Bok Village, Siem Bok District, Stung Treng Province.

The program aimed to strengthen connections among youth from different areas, encourage them to learn about natural resources and biodiversity conservation, and provide a platform to showcase their talents and creativity in contributing to their communities.

During the camp, all participants had a great time and lots of laughter through various fun activities such as team-building games, quizzes, music and art performances. They shared experiences, enjoyed meals together, and formed many new friendships. The camp created a warm and joyful atmosphere filled with unforgettable memories for all the youth.



**Camping activity in Stung Treng (above)**



## Standing with Displaced Families in Preah Vihear During Times of Crisis

PNKS provided urgent humanitarian assistance to 844 displaced families across five districts in Preah Vihear Province. With the generous support of our donors, emergency relief items, including food supplies, clean water, hygiene materials, sleeping mats, mosquito nets, and temporary shelters, were distributed to families seeking safety in pagodas, commune centers, and host communities. This timely support helped ease immediate hardships, restore dignity, and provide a sense of security for families facing uncertainty. PNKS extends heartfelt thanks to our donors and partners whose compassion and solidarity made it possible to reach those most in need during this critical time.



## Honoring Indigenous Voices: Protecting Rights and Shaping the Future in a Digital World

In celebration of the 31st International Day of the World’s Indigenous Peoples and the 21st National Indigenous Peoples Day in Cambodia, this program was organized under the theme “Protecting Rights and Shaping the Future of Indigenous Peoples in the Context of Digital Transformation.” The event created a meaningful space for Indigenous communities to come together, reflect on their rights, and celebrate the richness of their identities and traditions. Through open dialogue and shared learning, the program aimed to strengthen community understanding of Indigenous rights, encourage the protection of cultural heritage, and inspire greater respect and appreciation from the wider public.

P N K S

# សារព័ត៌មាន



## ពីភាពស្ងៀមស្ងាត់ទៅកាន់ភាពរឹងមាំ

ស្រីផា រស់ពីឃុំកាងចាម បានចែករំលែកថា មុនពេលចូលរួមក្លឹបយុវជន SKYE ដែលគាំទ្រដោយ PNKS គាត់គឺត្រឹមតែជាមេផ្ទះតែប៉ុណ្ណោះ។ នាងគ្មានទំនុកចិត្តក្នុងការនិយាយមុខសាធារណៈ ឬចូលរួមសកម្មភាពសហគមន៍ឡើយ ហើយក៏មិនមានប្រាក់ចំណូលផ្ទាល់ខ្លួន ដូច្នេះនាងមិនធ្លាប់ស្រមៃពីអនាគតលើសពីជីវិតក្នុងផ្ទះទេ។

តាមរយៈការបណ្តុះបណ្តាល និងការលើកទឹកចិត្តជាបន្តបន្ទាប់ពី PNKS ស្រីផាបានរកឃើញសំឡេងរបស់ខ្លួន បង្កើនទំនុកចិត្ត និងចាប់ផ្តើមចូលរួមយ៉ាងសកម្មក្នុងសកម្មភាពយុវជន និងសហគមន៍។ ការផ្លាស់ប្តូរនេះបានបើកឱកាសថ្មីៗ ហើយនៅខែមិថុនា ឆ្នាំ២០២៥ នាងទទួលបានការងារប្រាក់ខែជាមួយក្រុមហ៊ុន Amino-G Eco Handicraft។ ពីមនុស្សដែលមិនមានប្រាក់ចំណូលផ្ទាល់ខ្លួន សព្វថ្ងៃនាងរកចំណូលបាន ២៥០ ដុល្លារមួយខែ គាំទ្រខ្លួនឯង និងគ្រួសារ ខណៈពេលចូលរួមបំពេញការងារផ្នែកកាត់តរដេរអូ និងទំនាក់ទំនងនៅក្នុងខេត្តចំនួនប្រាំ។ សព្វថ្ងៃ ស្រីផាគឺជានារីវ័យក្មេងដែលមានទំនុកចិត្ត សេចក្តីថ្លៃថ្នូរ គោលបំណង និងសង្ឃឹមចំពោះអនាគត។

## ពីការរើសអើងទៅកាន់ភាពជាអ្នកដឹកនាំ៖ ដំណើររឿងនៃក្តីសង្ឃឹមរបស់លោក រិន រ៉ុំ

មុនពេលចូលរួមជាមួយអង្គការ PNKS លោក រិន រ៉ុំ រស់នៅដោយប្រឈមមុខនឹងការលំបាកជាច្រើន ទាំងផ្នែកជីវភាព និងការរើសអើងដោយសារពិការភាពរបស់គាត់។ ប៉ុន្តែសព្វថ្ងៃនេះដោយមានការគាំទ្រពី PNKS លោកក្លាយជាកសិករគំរូ និងទទួលបានផ្ទះសំណាញ់ទំហំ ៦ x ១៥ ម៉ែត្រ។ នៅក្នុងនោះ លោកបានដាំស្ពៃខ្មៅ ស្ពៃក្តោប និងខាត់ណាចិន។ ពីផលដំណាំរបស់លោក រិនរ៉ុំ លោកអាចលក់បាន ១៥ គីឡូក្រាម ទទួលបានប្រាក់ចំណូល ៦០,០០០ រៀល ហើយបានបន្តផលិត និងលក់បន្លែជាប្រចាំ។ ប្រាក់ចំណូលនេះបានជួយទិញសម្ភារៈសិក្សាសម្រាប់កូនៗ ទិញគ្រាប់ពូជ និងជួយគ្រប់គ្រងចំណាយប្រចាំថ្ងៃក្នុងគ្រួសារ។ កសិដ្ឋានតូចរបស់លោកបានប្រែប្រួលទៅជារឿងពោរពេញទៅដោយក្តីសង្ឃឹម។

ក្រៅពីការកសិកម្ម ការផ្លាស់ប្តូរដ៏ធំបំផុតនៅក្នុងជីវិតលោក រិន រ៉ុំ គឺការផ្លាស់ប្តូរការដែលសហគមន៍មើលឃើញលោក និងរបៀបដែលការជឿជាក់របស់លោកលើខ្លួនឯង។ ពីមនុស្សដែលតែងតែត្រូវបានផាត់ចោលពីការប្រជុំ ឥឡូវនេះលោកក្លាយជាអនុប្រធានក្រុមអភិវឌ្ឍន៍គំនិតផ្តួចផ្តើមសហគមន៍ (CIDG)។ តាមរយៈវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ បច្ចេកទេសកសិកម្ម ការប្រមូលធនធាន និងការយល់ដឹងអំពីពិការភាព លោកមានទំនុកចិត្ត និងសមត្ថភាពកាន់តែខ្លាំងជាងមុន។ បច្ចុប្បន្ន អង្គការដូចជា ADRA និង Plan បានទទួលស្គាល់សមត្ថភាពរបស់លោក និងជ្រើសរើសលោកជាជនបង្គោល។ ដំណើររឿងរបស់លោករិន រ៉ុំ បង្ហាញថា ពេលមនុស្សម្នាក់ត្រូវបានផ្តល់ឱកាសចូលរួមរៀនសូត្រ មានការគោរពពីអ្នកដទៃ និងមានការជឿជាក់ គាត់នឹងអាចក្លាយជាអ្នកដឹកនាំ មិនត្រឹមសម្រាប់ខ្លួនឯងទេ ប៉ុន្តែសម្រាប់សហគមន៍ទាំងមូលផងដែរ។



## កម្មវិធីយុវជនបោះតង់ក្រោមប្រធានបទ “យុវជនអ្នកបន្តវេន ការពារធនធានធម្មជាតិជីវចំរុះ ដើម្បីភពផែនដី”

អង្គការពន្លឺនៃក្តីសង្ឃឹម តាមរយៈគម្រោងសម្លេងព្រៃឡង់ព្រះវិហារ និងស្ទឹងត្រែង និងអង្គការ EHE បានរៀបចំកម្មវិធីយុវជនបោះតង់ក្រោមប្រធានបទ “យុវជនអ្នកបន្តវេន ការពារធនធានធម្មជាតិជីវចំរុះ ដើម្បីភពផែនដី” នៅភូមិសៀមបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

កម្មវិធីនេះមានគោលបំណងផ្សារភ្ជាប់ទំនាក់ទំនងរវាងយុវជនមកពីតំបន់នានា ជម្រុញឲ្យយុវជនចូលរួមស្វែងយល់ពីធនធានធម្មជាតិ និងការពារធនធានជីវចំរុះ ព្រមទាំងបង្ហាញទេពកោសល្យ និងភាពច្នៃប្រឌិតក្នុងការចូលរួមជួយសង្គម។

ក្នុងអំឡុងពេលបោះជំរុំ យុវជនទាំងអស់មានការសប្បាយរីករាយជាមួយសកម្មភាពជាច្រើនដូចជា លេងល្បែងជាក្រុម លេងសំនួរចម្លើយ ការសម្តែងតន្ត្រី និងការសម្តែងសិល្បៈ។ ពួកគេបានចែករំលែកបទពិសោធន៍ សើចសប្បាយរួមគ្នា និងបានបង្កើតមិត្តភាពថ្មីជាច្រើន។ ការបោះជំរុំនេះបានផ្តល់អារម្មណ៍កក់ក្តៅ និងការចងចាំល្អៗជាច្រើនសម្រាប់យុវជនទាំងអស់។



កម្មវិធីយុវជនបោះតង់នៅខេត្តស្ទឹងត្រែង



## ឈរជាមួយគ្រួសារជនភៀសសឹកនៅខេត្តព្រះវិហារ

ជាការឆ្លើយតបទៅកាន់ស្ថានភាពលំបាកនៃជនភៀសសឹកដែលត្រូវបង្ខំចាកចេញពីលំនៅឋាន ដោយសារភាពតានតឹងតាមបណ្តោយព្រំដែន អង្គការ PNKS បានផ្តល់ជំនួយមនុស្សធម៌បន្ទាន់ និងចាំបាច់ដល់គ្រួសារជនភៀសសឹកចំនួន ៨៤៤ គ្រួសារ ដែលស្ថិតក្នុងស្រុកចំនួន ៥ នៃខេត្តព្រះវិហារ។ ដោយមានការគាំទ្រពីម្ចាស់ជំនួយ សម្ភារៈជំនួយសំខាន់ៗមានដូចជា ស្បៀងអាហារ ទឹកស្អាត សម្ភារៈអនាម័យ កន្ទេល មុង និងតង់សម្រាប់ស្នាក់នៅបណ្តោះអាសន្ន ត្រូវបានប្រគល់ជូនដល់គ្រួសារដែលកំពុងស្វែងរកទីទួលសុវត្ថិភាពនៅតាមវត្តអារាម សាលាឃុំ និងសហគមន៍ម្ចាស់ផ្ទះ។ ជំនួយទាំងអស់នេះបានជួយសម្រាលបន្ទុក និងផ្តល់ការរស់នៅប្រកបដោយសុវត្ថិភាពដល់គ្រួសារទាំងអស់។




## លើកតម្កើងសំឡេងជនជាតិដើមភាគតិច៖ ការការពារសិទ្ធិ និងតម្រង់ទិសអនាគតក្នុងបរិបទឌីជីថល

ក្នុងឱកាសអបអរសាទរ ទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក លើកទី៣១ និង ទិវាជនជាតិដើមភាគតិចជាតិនៅកម្ពុជា លើកទី២១ កម្មវិធីនេះត្រូវបានរៀបចំឡើងក្រោមប្រធានបទ «ការការពារសិទ្ធិ និងការតម្រង់ទិសអនាគតជនជាតិដើមភាគតិច ក្នុងបរិបទបរិវត្តកម្មឌីជីថល»។ កម្មវិធីបានបង្កើតជាវេទិការមួយដ៏មានន័យ សម្រាប់សហគមន៍ជនជាតិដើមភាគតិចបានជួបជុំ ចែករំលែក និងរំលឹកអំពីសិទ្ធិ អត្តសញ្ញាណ និងវប្បធម៌ប្រពៃណីដ៏មានតម្លៃរបស់ខ្លួន។ តាមរយៈការសន្ទនា និងការរៀនសូត្រជាមួយគ្នា កម្មវិធីនេះមានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិជនជាតិដើមភាគតិច ការពារកេរ្តិ៍ដំណែលវប្បធម៌ និងជំរុញឱ្យមនុស្សក្នុងសង្គមទូទៅគោរព និងផ្តល់តម្លៃចំពោះសហគមន៍ជនជាតិដើមភាគតិច។ កម្មវិធីនេះសបញ្ជាក់យ៉ាងច្បាស់ថា សំឡេង ចំណេះដឹង និងវប្បធម៌របស់ជនជាតិដើមភាគតិច នៅតែមានតួនាទីសំខាន់ក្នុងការតម្រង់ទិសអនាគត ទោះបីជាពិភពលោកកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សក៏ដោយ។